01581782

លេខ / No: D361

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត
កាលបរិច្ឆេទ ៖ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨
ភាសាដើម ៖ ខ្មែរ
ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 08 / 2018
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

# ដីកាសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

01581783



## I. ប្រវត្តិនីតិវិធី

១. អោ អាន ពីមុនស្ថិតនៅក្នុងសំណុំរឿង ០០៤ ហើយឥឡូវនេះស្ថិតនៅក្នុងសំណុំរឿង ០០៤/២។ ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះបានចុះបញ្ជីនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៥ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៧ និងថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៨។

២. ចាប់តាំងពីបើកកិច្ចស៊ើបសួរសំណុំរឿងនេះមក មានមនុស្សចំនួន ១៩២០ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

៣. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស.ច.ស បានប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamill និង សេង ចាន់ធារី មិនអាចទទួលយកបានឡើយ[1]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ បានប្តឹងជំទាស់ទៅនឹងដីកាសម្រេចរបស់ ស.ច.ស[2]។

៤. នៅថ្ងៃទី១៤ និង ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ អង្គបុរេជំនុំជម្រះ("អ.ប.ជ") មិនអាចរកសម្លេងភាគច្រើនគ្រប់គ្រាន់ ដើម្បីសម្រេចសេចក្តីលើបណ្តឹងជំទាស់របស់អ្នកដាក់ពាក្យសុំទាំងពីរបានឡើយ[3]។

---

[1] សំណុំរឿង០០៤/២-D5/1/3 *ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី* ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ សំណុំរឿង០០៤/២-D5/2/3 *ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill* ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

[2] សំណុំរឿង០០៤/២-D5/1/4/1 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។ សំណុំរឿង ០០៤ -D5/2/4/2 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamill* ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១។

[3] សំណុំរឿង០០៤/២-D5/2/4/3 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Robert Hamill* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ សំណុំរឿង០០៤/២-D5/1/4/2 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សេង ចាន់ធារី* ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២។

01581784



៥. នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ សេង ចាន់ធារី បានដកពាក្យសុំរបស់គាត់ចេញពីសំណុំរឿង[4]។ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត("ក.ស.ចៅ.ស") បានទទួលស្គាល់ការដកពាក្យសុំនេះ តាមរយៈលិខិតចុះថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៤[5]។

៦. នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១១ Robert Hamill បានស្នើសុំឲ្យ ស.ចៅ.ស ពិចារណាឡើងវិញលើដីកាសម្រេចអំពីភាពអាចទទួលស្គាល់គាត់ជាដើមបណ្តឹងរដ្ឋប្បវេណី[6]។ ស.ចៅ.ស មិនបានចេញដីកាសម្រេចថ្មីលើភាពអាចទទួលស្គាល់គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីទេ។

៧. នៅក្នុងអំឡុងពេលស៊ើបសួរសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/១ និង សំណុំរឿង ០០៤/២ ក.ស.ចៅ.ស ត្រូវបានជូនដំណឹងឲ្យដឹងថា អ្នកដាក់ពាក្យសុំចំនួន ៤៧ នាក់ នៅក្នុងសំណុំរឿង ០០៤/២ បានទទួលមរណភាព[7]។ សិទ្ធិវ័ន្តរបស់អ្នកដាក់ពាក្យសុំម្នាក់ដែលទទួលមរណភាព បានបង្ហាញឆន្ទៈចង់ក្លាយជាអ្នកបន្តបណ្តឹងជំនួសអ្នកស្លាប់[8]។ អ្នកដាក់ពាក្យសុំចំនួន បី នាក់ បានដកពាក្យវិញ[9]។

---

[4] សំណុំរឿង០០៤/២-D5/1/5 *សំណើសុំដកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 11-VSS-00001 របស់ សេង ចាន់ធារី* ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤។

[5] សំណុំរឿង០០៤/២-D5/1/6 *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី ជួង ជូងី* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។ សំណុំរឿង០០៤/២-D5/1/7 *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី សំ សុគង់* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។ សំណុំរឿង០០៤/២-D5/1/8 *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី Emmanuel Jacomy* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។

[6] សំណុំរឿង ០០៤/២-D5/2/5 *សំណើសុំសហចៅក្រមស៊ើបអង្កេត ពិចារណាឡើងវិញលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ROBERT Hamill (D11/2/3)* ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១។

[7] ឧបសម្ព័ន្ធ ឃ *អនុស្សរណៈពីអង្គភាពគាំពារជនរងគ្រោះផ្ញើជូន ក.ស.ចៅ.ស* ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៨។ ឧបសម្ព័ន្ធ ង *អង្គភាពគាំពារជនរងគ្រោះ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព* ។ សំណុំរឿង ០០៤/២-D348.2 *ឧបសម្ព័ន្ធ ២* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤-D219/856 *របាយការណ៍នៃសកម្មភាពស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦។ សំណុំរឿង ០០៤/១-D307 *ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ៧។

[8] សំណុំរឿង ០០៤/២-D5/641/3 *លិខិតពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អំពី"សិទ្ធិវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបាន ទទួលមរណភាពដើម្បីបន្តការទាមទារសំណងរដ្ឋប្បវេណី ឯកសារលេខ D5/641"* ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៦។

[9] សំណុំរឿង ០០៤/២ -D5/1114/3 *លិខិតផ្ញើជូនមេធាវី* ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង ០០៤/២-D5/1921/3 *លិខិតផ្ញើជូនមេធាវី អំពីការដកលោក ឌី ដានី ចេញពីសំណុំរឿង ០០៣, ០០៤ និង ០០៤/២* ថ្ងៃទី ០៩ ខែ

៨. នៅក្នុងអំឡុងពេលស៊ើបសួរសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២ ក.ស.ច.ស បានស្តាប់ចម្លើយអ្នកដាក់ពាក្យសុំមួយចំនួននៅក្នុងសំណុំរឿង ០០៤/២ ចំណែកឯនៅក្នុងសំណុំរឿង ០០២ និង ០០២/១ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មអ្នកដាក់ពាក្យសុំពីសំណុំរឿង ០០៤/២។

៩. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៦ និងថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្គាប់ឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ត្រូវមានអ្នកតំណាងផ្នែកច្បាប់[10] ហើយលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិបន្ថែមទៀត បានដាក់ចូលក្នុងសំណុំរឿងរួចហើយចាប់តាំងពីពេលនោះមក។ ហេតុនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានអ្នកតំណាងផ្លូវច្បាប់ហើយ។

១០. នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធសំណើទាំងអស់របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ ដែលស្នើសុំវិធានការការពារ[11]។

## II. **ការពិភាក្សា**

១១. ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ និងបង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយក្នុងចំណោមបទឧក្រិដ្ឋជាច្រើន ដែលត្រូវបាន

---

មករា ឆ្នាំ ២០១៨។ សំណុំរឿង ០០៤/១-D307 *ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ៧។

[10] សំណុំរឿង ០០៤/២- D330 *ដីកាសម្រេចចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់* ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ សំណុំរឿង ០០៤/២-D346 *ដីកាសម្រេចទទួលស្គាល់មេធាវី និងការចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧។

[11] សំណុំរឿង ០០៤/២-D348 *ដីកាសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧។

ចោទប្រកាន់លើជនត្រូវចោទ ថា ខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព[12]។

១២. វិធានផ្ទៃក្នុង ២៣*ស្ទួន* ចែងថា ស.ច.ស ត្រូវចេញសេចក្ដីសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងយូរបំផុត គឺនៅពេលចេញដីកាដំណោះស្រាយ។

១៣. នៅថ្ងៃនេះ យើងបានលើកលែងការចោទប្រកាន់ទាំងអស់នៅក្នុងសំណុំរឿង ០០៤/២ ពីព្រោះថា អោ អាន ដែលជាជនត្រូវចោទតែម្នាក់គត់នៅក្នុងសំណុំរឿងនេះ មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឡើយ។

**តាមសំអាងហេតុខាងលើ យើង ៖**

១៤. **បដិសេធ** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៤/២។

ថ្ងៃព្រហស្បតិ៍ ០៥ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨

**សហចៅក្រមស៊ើបអង្កេតជាតិ**

National Co-Investigating Judge

Co-Juge d'instruction national

**យូ ប៊ុនឡេង**

[12]អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី ៩)("វិធានផ្ទៃក្នុង") វិធាន ២៣*ស្ទួន*(១)។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សេចក្ដីណែនាំស្ដីពីការចូលរួមរបស់ជនរងគ្រោះ (វិសោធនកម្មលើកទី ១) ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ មាត្រា ៣.២។